អង្គការសហការ
INTERNATIONAL COOPERATION CAMBODIA

អង្គការសហការ
អន្តរជាតិ កម្ពុជា



# របាយការណ៍
# ប្រចាំឆ្នាំ២០១២

# របាយការណ៍អង្គការសហការអន្តរជាតិកម្ពុជា (អាយស៊ីស៊ី) ប្រចាំឆ្នាំ ២០១២

## ព្រឹត្តិការណ៍សំខាន់ៗ ក្នុងឆ្នាំ២០១២

នៅឆ្នាំ២០១២ អង្គការអាយស៊ីស៊ី មានសកម្មភាពដែលគួរឱ្យចាប់អារម្មណ៍ និង វិជ្ជមានជាច្រើន។ ចំពោះគម្រោងយើងបានធ្វើការយ៉ាងសស្រាក់សស្រាំដើម្បីបង្កើតកម្មវិធីថ្មីមួយឈ្មោះថា កម្មវិធីការអប់រំ និង អភិវឌ្ឍសហគមន៍ដោយផ្អែកលើអត្តសញ្ញាណ (អាយប៊ីស៊ីឌីអុី)។ អាយប៊ីស៊ីឌីអុី ដាក់បញ្ចូលគ្នា នូវអតីតគម្រោង អាយស៊ីស៊ី ចំនួន៣ដែលមានទីតាំងនៅក្នុង ខេត្តរតនគិរី និង មណ្ឌលគិរី ពោលគឺៈ គម្រោងរាយជ៍ រីដ និង ប៊ីស៊ីអាយប៊ីអុី ។ យើងរៀបចំផែនការឱ្យ កម្មវិធី អាយប៊ីស៊ីឌីអុី ថ្មីនេះធ្វើការលើផ្នែកអប់រំពីរភាសារបស់ អាយស៊ីស៊ី ក្នុងចំណោមជនជាតិដើមភាគតិចក្នុងកម្រិតមួយផ្សេងទៀតដោយប្រើវិធីសាស្ត្រល្អជាងមុនក្នុងការចូលរួមជាមួយសហគមន៍។

ការផ្តួចផ្តើមរយៈពេលវែងមួយទៀតរបស់ អាយស៊ីស៊ី គឺ "គម្រោងស្ពាយ" ដែលបានធ្វើការយ៉ាងសស្រាក់សស្រាំដើម្បីរៀបចំ និង ចុះបញ្ជីជាអង្គការមិនមែនរដ្ឋាភិបាល ក្នុងស្រុក។ ទម្រង់បែបបទស្នើសុំត្រូវបានអនុម័តយល់ព្រម និង ចាប់ពី ថ្ងៃទី១ ខែមករា ឆ្នាំ២០១៣ តទៅ គម្រោង ស្ពាយ លែងជាគម្រោងរបស់អាយស៊ីស៊ី ទៀតហើយ ប៉ុន្តែជាអង្គការ មិនមែនរដ្ឋាភិបាល ក្នុងស្រុកមួយឈ្មោះថា "ម្លប់ឫស្សី"។

អាយស៊ីស៊ីទទួលបានព្រះពរ ដោយសារមានដៃគូ ផ្តល់ជំនួយរយៈពេលវែង និងមានការប្តេជ្ញាចិត្តខ្ពស់ដែលជួយលើផ្នែកហិរញ្ញវត្ថុ និងរួមសហការជាមួយ អាយស៊ីស៊ីដើម្បីលើកស្ទួយជីវភាព របស់ប្រជាជន និង សហគមន៍ក្នុងប្រទេសកម្ពុជា។ នៅឆ្នាំ ២០១២ យើងបានពង្រីកបណ្តាញដៃគូផ្តល់ជំនួយ និង ស្វាគមន៍ដោយក្តីសោមនស្សរីករាយចំពោះ "ជំនួយបាទីស្ទ ពិភពលោក នៃប្រទេសអូស្ត្រាលី" ដែលបានក្លាយជាដៃគូ ផ្តល់ជំនួយរបស់ យើង។ អាយស៊ីស៊ី ក៏ទទួលបានព្រះពរផងដែរ ដែលមានកិច្ចរួមសហការល្អនិងប្រកបដោយផ្លែផ្កាជាមួយ រដ្ឋាភិបាលកម្ពុជា និង ក្រសួងនានា។ ទំនាក់ទំនងជា មួយ "ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនិតិសម្បទា" បានចាប់ផ្តើមឡើងជាវិជ្ជមាន ដើម្បីឈានទៅរកកិច្ចរួមសហការខ្លាំងក្លាជាងមុនកាលពីឆ្នាំ២០១២។

នៅឆ្នាំ២០១២ ដដែល គណៈកម្មការក្រុមប្រឹក្សាភិបាលរបស់អាយស៊ីស៊ី បានបើកកិច្ចប្រជុំជាច្រើនលើក ដើម្បីជ្រើសរើសនាយកប្រតិបត្តិ ថ្មីមួយរូប។ យោងតាម អនុសាសន៍ ក្នុងអង្គប្រជុំ ក្រុមប្រឹក្សាភិបាលបានជ្រើសរើសអ្នកស្រី ស៊ូសាន ថៅវ៉ា ម៉ាតសេន ជានាយកប្រតិបត្តិ នៃអង្គការអាយស៊ីស៊ី ចាប់តាំងពី៣ក់កណ្តាល ខែវិច្ឆិកា ឆ្នាំ ២០១២។



## លទ្ធផលសង្ខេប ពីផ្នែក យុទ្ធសាស្ត្រសំខាន់ៗ របស់អាយស៊ីស៊ី

<u>ជនជាតិដើមភាគតិច</u>

ជនជាតិដើមភាគតិចជាក្រុមគោលដៅ យុទ្ធសាស្ត្រមួយរបស់ អាយស៊ីស៊ី ក្នុង ឆ្នាំ២០១២។ អាយស៊ីស៊ី បានជួយ

អភិវឌ្ឍ សមត្ថភាព អ្នកដឹកនាំភូមិ តាមរយៈគណៈកម្មការ ភាសាដែលតម្រូវឱ្យជួយកត់ត្រា រឿងប្រពៃណីនិង ប្រវត្តិសាស្ត្រ ស្រាវជ្រាវពាក្យនិងការប្រើប្រាស់ពាក្យតាមបរិបទ ក្នុងតំបន់ និង កែសម្រួលរឿង ដែលបុគ្គលិក អាយស៊ីស៊ី រៀបចំដើម្បីបោះពុម្ព។ សមាជិកគណៈកម្មការ ភាសា ទាំងនេះដើរតួ ជាធនធាន មួយដ៏សំខាន់ចំពោះ សហគមន៍នាពេលអនាគត ព្រោះថាគាត់បានទទួលការបណ្តុះបណ្តាល ពីរបៀប អភិរក្ស និងកត់ត្រាភាសា និង វប្បធម៌របស់ សហគមន៍។ ថ្នាក់អក្ខរកម្ម (ជាភាសា ព្នង ព្រៅ គ្រឹង ទំពួន និង ខ្មែរ) បង្រៀនពី ការអាន និង ការសរសេរ ក៏ដូចជា បំណិនជីវិត ដើម្បីលើកស្ទួយជីវភាព ឱ្យមាននិរន្តរភាព។

បុគ្គលសំខាន់ៗ មកពីសហគមន៍ជនជាតិដើម ព្នងក្នុងខេត្តមណ្ឌលគិរី បានទាក់ទងយ៉ាងសកម្ម ជាមួយសាលារៀន និង ថ្នាក់អក្ខរកម្ម ដើម្បីបញ្ចូល វប្បធម៌និងភាសាព្នង ក្នុងការសិក្សា របស់សិស្ស។ កិច្ចការនេះបានពង្រីក បន្ថែមហួសពីសាលារៀនដើម្បីជួយដល់សហគមន៍ ឱ្យគិតអំពីការផ្លាស់ប្តូរឆាប់រហ័ស វប្បធម៌ និង ជីវភាពរបស់គាត់ដែលទាក់ទងយ៉ាងជិតស្និទ្ធ នឹងបញ្ហាដែលបានជួបប្រទះក្នុងវិស័យអប់រំ។ ឥឡូវ បុគ្គលសកម្ម ដែលមកពីសហគមន៍ជនជាតិដើមព្នង ទាំងនេះបានបង្កើតជា បណ្តាញប្រឹក្សាយោបល់សហគមន៍ព្នង នៅទូទាំងខេត្ត ព្រមទាំងមានការជួបជុំគ្នាយ៉ាងទៀងទាត់ដើម្បី ដោះស្រាយបញ្ហា ដែលពួកគាត់បានចាត់អាទិភាពខ្ពស់បំផុត។

## ក្រុមគ្រួសារ

ក្នុងបរិបទ ប្រទេសកម្ពុជា កុមារភាគច្រើនទទួលបានការចិញ្ចឹមបីបាច់ពីឪពុកម្តាយផ្ទាល់ ឬ ញាត្តិសន្តាន។ អ្វីដែលសំខាន់បំផុតគឺកុមាររងឥទ្ធិពលពី គុណតម្លៃគ្រួសារ ជំនឿ និង បរិយាកាសសង្គម។ អាយស៊ីស៊ីបានដាក់ក្រុមគ្រួសារជាស្នូល ដើម្បីនាំឱ្យមានការបំផ្លាស់បំប្រែ និង សេចក្តីសង្ឃឹម ដល់សហគមន៍គោលដៅ។

នៅឆ្នាំ២០១២ អាយស៊ីស៊ីបានទទួលលទ្ធផលល្អៗ ច្រើនជាពិសេស ការផ្លាស់ប្តូរផ្នត់គំនិត និងឥរិយាបថ ឪពុកម្តាយចំពោះកូន។ ខុសពីពេលមុន ឪពុកម្តាយមានការយល់ដឹងច្រើនពី តួនាទីរបស់គាត់ និង តម្រូវការ របស់កូនៗ។ ជាលទ្ធផល ពួកគាត់អាចរិះរកមធ្យោបាយ សមស្រប ក្នុងការប្រាស្រ័យទាក់ទង ជាមួយកូន និង ប្រៀនប្រដៅកូន។ ក្រុមគ្រួសារទាំងនោះទទួលបានការ ពង្រឹងអំណាច ដើម្បីរកឱ្យឃើញនូវធនធានផ្ទាល់ខ្លួន និង ប្រើប្រាស់ការ ច្នៃប្រឌិត ដើម្បីចាប់ផ្តើម ធ្វើគម្រោងតូចៗ ដូចជា៖ ការដាំដំណាំចម្រុះ កសិដ្ឋានចិញ្ចឹមត្រី និង ចិញ្ចឹមសត្វដោយប្រើបច្ចេកទេសថ្មី។ ជាលទ្ធផល គ្រួសារទាំងនោះអាច ទ្រទ្រង់ការរស់នៅ របស់ពួកគាត់បាន ព្រមទាំងអាចបញ្ជូន កូនទៅសាលារៀនទៀតផង។ លើសពីនេះទៅទៀត ពួកគាត់អាចជាគំរូល្អ ដល់អ្នកជិតខាង តាមរយៈបទពិសោធន៍នៃការ ផ្លាស់ប្តូរជីវភាពរស់នៅ។ គ្រួសារមានភាព សប្បាយរីករាយដោយមាន ការងារធ្វើក្នុងតំបន់ជិតផ្ទះ និង អាចចំណាយពេលវេលា ជាមួយគ្រួសារ និងកូនៗបានច្រើនជាងមុន។

សំខាន់ជាងនេះទៅទៀត នៅឆ្នាំ២០១២ អាយស៊ីស៊ីបានធ្វើការ ដើម្បីលើកស្ទួយការយល់ដឹងអំពីសិទ្ធិកុមារ និងការគាំពារកុមារ ព្រមទាំងបាន ទាមទារការគាំទ្រមតិ លើគោលនយោបាយ សិទ្ធិកុមារ។ កិច្ចការនេះ បានធ្វើក្នុងចំណោមអង្គការសង្គមស៊ីវិល និង ដោយផ្ទាល់ ជាមួយអាជ្ញាធរថ្នាក់ជាតិ។

ម្យ៉ាងទៀត ក្មេងៗ ជាច្រើនដែលរស់នៅក្នុង មណ្ឌលកុមារកំព្រាបានជួបជុំជាមួយ ក្រុមគ្រួសាររបស់ពួកគេវិញ។ ក្រៅពីកិច្ចការដែលបានសម្រេចជោគជ័យ អាយស៊ីស៊ីសប្បាយរីករាយចំពោះទំនាក់ទំនង និងទំនុកចិត្តដែលបានកើតមានឡើងជាមួយក្រុមគ្រួសារគោលដៅ។ យើងសង្ឃឹមថា លទ្ធផលទាំងនេះ នឹងជះឥទ្ធិពលជា វិជ្ជមានដល់ សង្គមកម្ពុជា។



<u>បញ្ហាឆ្លងប្រព័ន្ធ (ស៊ីស៊ីអាយ)</u>

ការផ្តួចផ្តើមស៊ីស៊ីអាយ ដែលបានចែងក្នុងផែនការ យុទ្ធសាស្ត្រ របស់អាយស៊ីស៊ី ទាមទារឱ្យមានការអនុវត្ត លើបញ្ហា៣ផ្នែកក្នុង អង្គការអាយស៊ីស៊ី ទាំងមូល ពោលគឺៈ បញ្ញាស្មារតី បរិស្ថាន និង សមភាពយែនឌ័រ។ សកម្មភាពរបស់ស៊ីស៊ីអាយ បានចាប់ផ្តើម កាលពី ខែមិថុនាឆ្នាំ ២០១២ ដោយមានការជ្រើសរើសអ្នកតំណាង៨រូប ឱ្យចូលរួមក្នុងផ្នែកនីមួយៗ របស់ស៊ីស៊ីអាយ ដូច្នេះឥឡូវនេះ គម្រោងនីមួយៗ មានអ្នកតំណាង៣នាក់ចូលរួមក្នុងផ្នែកទាំងនោះ។

យើងបានធ្វើវគ្គសិក្ខាសាលា ចំនួន២កាលពីឆ្នាំ២០១២។ វគ្គសិក្ខាទី១ស្តីពី "បញ្ញាស្មារតី" ដែលលើកទឹកចិត្ត និង ពង្រឹងសមត្ថភាពសិក្ខាកាម ឱ្យលូតលាស់ ពេញលក្ខណៈផ្នែកស្មារតីដើម្បីផ្លាស់ប្តូរ ឫកពា ទម្លាប់ ឥរិយាបថ និង ផ្នត់គំនិត។ ក្នុងដំណើរការនេះ ពួកគាត់បានបង្កើនការយកចិត្តទុកដាក់និងគោរពគ្នា ទៅវិញ ទៅមក ព្រមទាំងការប្តេជ្ញាចិត្តជួយគ្នាក្នុងពេលចាំបាច់ ឬ គ្រាអាសន្ន។ ចំណែកឯ វគ្គសិក្ខាសាលាស្តីពី "សមភាពយែនឌ័រ" វិញ សិក្ខាកាមបានទទួល ចំណេះដឹង ការយល់ដឹង និង អភិវឌ្ឍជំនាញ និង ឫកពាត្រឹមត្រូវចំពោះបញ្ហាសមភាព យែនឌ័រ និង សិទ្ធិមនុស្ស។ ពួកគាត់ក៏បានទទួលចំណេះដឹង អំពីសមភាពយែនឌ័រ និង ការការពារស្ត្រី និងកុមារពីការ រំលោភបំពានក្នុងគ្រួសារនិងសហគមន៍។

ឥឡូវនេះ អ្នកតំណាង ស៊ីស៊ីអាយ កំពុងតែចែករំលែកចំណេះដឹងថ្មីៗ ដែលទទួលបានពីសិក្ខាសាលា ទាំង២នេះ ដល់ក្រុមការងារក្នុងគម្រោង និង សហគមន៍។

**ផែនការ ឆ្នាំ២០១៣**

ឆ្នាំ២០១៣ នេះជាឆ្នាំដែលអាយស៊ីស៊ី នឹងសង្កត់ធ្ងន់ទៅលើការពង្រីកការងារ របស់ខ្លួនផ្នែកអភិវឌ្ឍន៍ ដើម្បីបន្តជួយខាងបញ្ញាស្មារតី រាងកាយ និង សង្គម ដល់អ្នកដែលទទួលបានការយកចិត្ត ទុកដាក់តិចតួច ពោលគឺៈ ជនក្រីក្រ ជនងាយរងគ្រោះ និង ជនដែលគេមិនសូវឱ្យតម្លៃ ក្នុងប្រទេសកម្ពុជា។

កិច្ចការនេះ នឹងធ្វើឡើងដោយមានការ រួមសហការយ៉ាងពេញទំហឹង និងជិតស្និទ្ធជាមួយ សហគមន៍ក្នុងតំបន់ ដៃគូផ្តល់ជំនួយ និងអាជ្ញាធរ កម្ពុជាព្រមទាំង ភ្ជាប់បណ្តាញទំនាក់ទំនងជាមួយ អង្គការសង្គមស៊ីវិល ផ្សេងទៀត។



**សេចក្តីថ្លែងអំណរគុណ**

សូមអរគុណចំពោះអង្គការ និង ក្រសួងនានា ដែលគាំទ្រ និង ផ្តល់ជំនួយ ដ៏សប្បុរសដែលមានសារៈសំខាន់ ចំពោះ អាយស៊ីស៊ី ក្នុងការបំពេញការងារ របស់ខ្លួនក្នុងប្រទេសកម្ពុជាៈ

ក្រសួងការបរទេស, ក្រសួងអប់រំ យុវជន និង កីឡា, ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា, ក្រសួងអភិវឌ្ឍជនបទ, ក្រសួងសុខាភិបាល, **InterAct, Cambodia Action, SIL International, Normisjon, FELM, ERIKS, Tearfund UK, TEAR Australia, Danmission, BWAA,** ប្រិយសម្ពន្ធគ្រិស្តបរិស័ទកម្ពុជា **(EFC), CCC,** និង **MEDICAM.**



ការិយាល័យកណ្តាល
ផ្ទះលេខ ១C ភូមិត្នោតជ្រុំ ផ្លូវ៣៧១ កែងនិង២៦បេតេ
សង្កាត់បឹងទំពន់
ខ័ណ្ឌមានជ័យ
ទូរស័ព្ទលេខ៖ ០៩២ ៤៦៩ ៩៣៤
អ៊ីមែល៖ info@icc.org.kh,
គេហទំព័រ៖ www.icc.org.kh